KINGDOM OF CAMBODIA
Nation Religion King

MINISTRY OF EDUCATION YOUTH AND SPORT

No.:........171........MoEYS/Adm

Phnom Penh May 22, 2008

Mr. Luis Benveniste
Country Sector Coordinator,
Human Development Unit,
East Asia and Pacific Region,
The World Bank

**Subject: Education Sector Support Scale Up Action Programme: Environmental Management Plan and Ethnic Minorities Action Plan**

Referring to our letter 160 MoEYS/Adm dated May 16, 2008 the Ministry of Education, Youth and Sport requests for your approval of the Environmental Management Plan and Ethnic Minorities Action Plan of the ESSSUAP and seeks your kind assistance in disclosure of the said plans in your INFORSHOP. The above plans are enclosed to this letter.

The Ministry of Education, Youth and Sport will disclose the two plans in its Ministry's website next week and the Khmer version of Ethnic Minorities Action Plan at schools in Rattanakiri, Mundulkiri and Preah Vihear provinces in the week of June 23, 2008 where the ESSSUAP Scholarship Programme will operate.

The Ministry would like to take this opportunity to express our sincere thanks to the World Bank team and the ESWG for their support and cooperation.

Sincerely,

Im Sethy
Secretary of State
Ministry of Education, Youth and Sport

Cc: H.E. Nath Bunroeun, Under Secretary of State, MoEYS
Members of Programme Management Committee
H.E. Chea Oeung, Director General of Finance and Administration
H.E. Keu Nay Leang, Director General of Education

# ផែនការសកម្មភាពសំរាប់ជនជាតិភាគតិច
# កម្មវិធីសកម្មភាពបង្កើនការគាំទ្រវិស័យអប់រំ

## គោលដៅអភិវឌ្ឍរបស់កម្មវិធី

ដើម្បីបង្កើនការរីកចំរើនក្នុងវិស័យអប់រំដែលសំដៅឱ្យកុមារដល់អាយុចូលរៀនបានចូលរៀន បង្កើនអត្រាពិតចូលរៀន ការនៅបន្តការសិក្សា អត្រារៀនឡើងថ្នាក់ និងអត្រារៀនចប់ថ្នាក់ទី៦។

អាំងឌីការទ័រលទ្ធផលនៅក្នុងផែនការយុទ្ធសាស្ត្រឆ្នាំ២០០៦-២០១០នឹងត្រូវយកមកប្រើដើម្បីតាមដានការរីកចំរើន។ ពេលណាដែលអាច ទិន្នន័យនឹងត្រូវបំពេកតាមឃុំ ករិតភាពក្រីក្រ យេសដ័រ ភាគការភាព និងជនជាតិភាគតិច ដើម្បីតាមលទ្ធផលកម្មវិធីដែលកើតមានលើក្រុមប្រជាពលរដ្ឋដែលលំបាក។

## សកម្មភាពរបស់កម្មវិធី

ថ្នាក់រៀនសំរាប់ការអប់រំកុមារតូច និងបឋមសិក្សានឹងត្រូវសាងសង់បន្ថែមទៅលើទីតាំងសាលារៀនបច្ចុប្បន្ន ដើម្បីផ្តល់នូវវដ្តនៃការអប់រំ ពីថ្នាក់មតេយ្យសិក្សា ដល់ថ្នាក់ទី៦។

តែបើទោះបីជាទីណាដែលមានសាលាគ្រប់គ្រាន់ មានគុណភាព កុមារអាចជួបបញ្ហាជាឧបសគ្គច្រើនពីឱកាសរៀនសូត្រ។ ដើម្បីឆ្លើយតប ជាដំបូង ក្រសួងអប់រំនឹងអនុវត្តយុទ្ធនាការទូទាំងប្រទេសដើម្បីកសាងការយល់ដឹងនៅក្នុងសហគមន៍អំពី កុមារអាយុ៦ឆ្នាំត្រូវដល់ពេលចូលរៀន និងផលលំបាកធ្ងន់ធ្ងរប្រសិនណាបើមិនបានឱ្យចូលរៀនទេនោះ។ ទីពីរ ក្រសួងអប់រំនឹងអនុវត្តអន្តរាគមន៍ដែលឆ្លើយតបនឹងតំរូវការរបស់កុមារ ដើម្បីដោះស្រាយបញ្ហាដែលមាននៅក្នុងគ្រួសារដែលធ្វើឱ្យកុមារមិនអាបន្តការចូលរៀនបាន ដោយជ្រើសរើសសិស្សថ្នាក់ទីបីនៅរៀនសាលាចំនួន ២០០ ក្នុងខេត្តបីដើម្បីសាកល្បង គឺ ខេត្ត មណ្ឌលគីរី ព្រះវិហារ និងរតនគីរី ដែលជាខេត្តក្រសួងរកឃើញថាមានការបោះបង់ការសិក្សាខ្ពស់ជាងនៃសិស្សសាលាបឋមសេក្សានៅក្នុងប្រទេស។ សិស្សដែលនឹងត្រូវបានជ្រើសរើសទាំងនោះនឹងទទួលនូវអាហារូបករណ៍ចំនួន ២០ ដុល្លាសហរដ្ឋអាមេរិកសំរាប់រយៈពេលមួយឆ្នាំពេលណាដែលគេនៅបន្តរការសិក្សា និងទទួលបាននូវពិន្ទុសិក្សាគ្រប់គ្រាន់សំរាប់ឡើងថ្នាក់ពីថ្នាក់ទី ៤ ដិលទី ៦។

បន្ថែមទៀត សាលានឹងទទួលបាននូវ ជំនួយឥតសំណងលើកកំពស់សាលារៀន ដើម្បីអនុវត្តនូវសកម្មភាពអទិភាពទាំងលាយដែលរកឃើញនៅពេលធ្វើការវាយតំលៃសាលារៀន និងការរៀបចំផែនការសាលារៀន។ ការវាយតំលៃសាលារៀននេះនឹងមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ដែលមានជនជាតិភាគតិច សំរាប់រកឱ្យឃើញនូវផលលំបាកដែលធ្វើមិនឱ្យសាលាមានប្រសិទ្ធិភាព និងវិៈរកមធ្យោបាយដើម្បីលើកកំពស់គុណផាពអនុវត្តការងាររបស់សាលារៀន។ ជំនួយឥតសំណងលើកកំពស់សាលារៀន នឹង ខឹតខំធ្វើឱ្យមានភាពស៊ីសង្វាក់គ្នានៃក្របខ័ណ្ឌចូលរួមក្នុងស្ថាប័នពី សមាជិកក្នុងសហគមន៍ ឪពុកម្តាយ មន្ត្រីសាលារៀន អប់រំស្រុក និងខេត្ត ដើម្បីជួយដោះស្រាយមូលហេតុដែលធ្វើឱ្យកុមាររៀនត្រួតថ្នាក់ ជួយការពារកុមារពីការបោះបង់ និងជួយឱ្យកុមារនៅក្រៅសាលាចូលរៀន។ របៀបធ្វើការបែបនេះនឹងជួយលើកកំពស់ និង កសាងសមត្ថភាពឆ្ពោះទៅរកវិមជ្ឈការយ៉ាងទូលាយលើដំណើរការនៃការធ្វើផែនការជំនាញ និងការគ្រប់គ្រង។

## សារៈប្រយោជន៏សង្គម និងការអប់រំ ដែលរំពឹងទុក

ប្រាក់អាហារូបករណ៏អាចជួយផ្ទាលឱ្យកុមាររួលរៀន ដោយវាផ្តល់ឱ្យគ្រួសារក្រីក្រផ្ទាល់នូវធនធាន ក៏ដូចជាមិនផ្ទាល់ជំនួសឱ្យការដែលកុមារពលកម្មមកចូលរៀនមិនបានជួយគ្រួសារ។ ប្រហែលជា ១៨,០០០ សិស្សនៅក្នុងខេត្តទាំងបី នឹងរំពឹងថាទូលប្រយោជន៏ពីអាហារូបករណ៏ដែលផ្តល់ដោយ កម្មវិធីសកម្មភាពបង្កើនការគាំទ្រវិស័យអប់រំ នៅចន្លោះឆ្នាំ ២០០៨ ដល់ ២០១២។ អាហារូបករណ៏សំរាប់សិស្សនារីអនុវិទ្យាល័យនៅតាមខេត្តដាច់ស្រយាល ដែលមានជាច្រើននូវសិស្សជនជាតិភាគតិច បានបង្កើនការចូលរៀន និងធ្វើឱ្យសិស្សអាហារូបករណ៏រៀនជាបន្តនៅសាលាក្នុងចន្លោះពី៣០ ទៅ ៤០ ក៏រិតភាគរយ។

ចំពោះបរិមាណទឹកប្រាក់អាហារូបករណ៏ ការសិក្សាសង្គមសេដ្ឋកិច្ចនៅប្រទេសកម្ពុជាឆ្នាំ២០០៤ផ្តល់នូវបរិមាណប៉ាន់ស្មានលើការចំណាយផ្ទាល់សំរាប់ការអប់រំ ដែលជាមធ្យមសំរាប់សិស្សថ្នាក់ទី៥ គឺ តិចជាង ២០ ដុល្លាអាមេរិកបន្តិច។ បរិមាណប៉ាន់ស្មាននេះមិនរាប់បញ្ចូលតំលៃដែលកុមារអាចរកចំណូលបានប្រសើនបើមិនទៅរៀននោះទេ ។ ILO/UNICEF/WB ប៉ាន់ស្មានថា ជាមធ្យម កុមារម្នាក់រកបាន ១ ដុល្លាអាមេរិកក្នុងមួយថ្ងៃ ដែលជាបរិមាណ ២៨ ផាគរយនៃចំណូលគ្រួសារ។ មុនពេលមានអាយុ ១០ ឆ្នាំ ៥០ភាគរយនៃកុមារនៅស្រុកខ្មែរធ្វើការ ហើយកុមារដែលបានទៅរៀនឃើញថាមានចំនួនធ្វើការថយចុះជាខ្លាំង។ ទោះជាយ៉ាងណាក៏ដោយ បទពិសោធន៏ពីកម្មវិធីអាហារូបករណ៏អនុវិទ្យាល័យ ឃើញថាការជួយត្រឹមតែផ្តល់ប្រាក់ដែលកុមារត្រូការដើម្បីទៅរៀន ក៏មានឥទ្ធិពលខ្លាំងក្លាឱ្យកុមារបានរក្សាការរៀនសូត្រដែរ។

នៅឆ្នាំ១៩៩៧ គណៈកម្មការអន្តរក្រសួងពិសេស សំរាប់ការអភិវឌ្ឍប្រជាជនខ្ពង់រាប បានចេញនូវ គោលនយោបាយ ទូទៅសំរាប់ការអភិវឌ្ឍប្រជាជនខ្ពង់រាប ។ ពង្រាងគោលនយោបាយនេះ បានមកដោយដំណើរការប្រឹក្សាយ៉ាងខ្ពង់ខ្ពស់ពី ប្រជាជនមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល ទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិ និងរដ្ឋាភិបាល និងដាក់ស្តែង កម្មវិធីអាហារូបករណ៍ ជាវិធានការណ៍ដាក់ស្តែងអនុវត្តគោលនយោបាយនេះ ។

## សង្ខេបពីការប្រឹក្សាយោបល់

ជោគជ័យពីការអនុវត្តកម្មវិធីអាហារូបករណ៍នៅអនុវិទ្យាល័យ យល់ដឹងជាសាធារណៈនិងពីការស្រាវជ្រាវ បាននាំមកនូវអនុសាសន៍សាកល្បងអនុវត្តកម្មវិធីអាហារូបករណ៍នៅវិថមសិក្សា ។ នៅមានសំនួរជាច្រើនទៀតជាមួយនឹងកម្មវិធីនេះ រួមមានតើត្រូវធ្វើដូចម្តេចដើម្បីឱ្យកម្មថ្មីនេះមានប្រសិទ្ធភាព ។ ដូចនេះ កម្មវិធីសាកល្បងនេះត្រូវបានភ្ជាប់ជាមួយនូវសមាសភាគវិភាគយ៉ាងច្បាស់លាស់ រួមមាន ការស្រាវជ្រាវលើផលជះ និងការសិក្សាតាមផ្ទះ ដើម្បីវាយតំលៃពីការយល់ឃើញរបស់គ្រួសារលើអាហារូករណ៍ផ្តល់ឱ្យ និងមូលហេតុដែលនាំឱ្យកុមារចូលរៀន ឬបោះបង់ការសិក្សា ។

## ដំណើរការអនុវត្ត

សៀវភៅអាហារូបករណ៍បានរៀបចំឡើង ដែលមានមូលដ្ឋានពីកម្មវិធីអាហារូបករណ៍អនុវិទ្យាល័យរបស់ក្រសួង អប់រំ យុវជន និងកីឡា ។ គណៈកម្មការគ្រប់គ្រងមូលដ្ឋាន នៃសាលាត្រូវទទួលអាហារូបករណ៍ និងមន្ត្រីអប់រំនឹងទទួលការបណ្តុះបណ្តាលឱ្យប្រើសៀវភៅនេះ ។

គណៈកម្មការគ្រប់គ្រងមូលដ្ឋាននឹងគ្រប់គ្រងកម្មវិធីអហារូបករណ៍បឋមសិក្សានេះ តាមដានការចូលរៀន និងការរៀនសូត្រ របស់សិស្សអាហារូបករណ៍ ។ សមាសភាគ គណៈកម្មការគ្រប់គ្រងមូលដ្ឋាន មាន:

| | |
|---|---|
| ១ នាយក ឬនាយករងសាលាបឋមសិក្សា | ប្រធាន |
| ២ តំណាងសហគមន៍ម្នាក់ បើអាចជាជនជាតិភាគតិច ពីគណៈកម្មការគាំទ្រសាលាបឋមសិកសា | អនុប្រធាន |
| ៣ គណនេយ្យករសាលារៀន | ហិរញ្ញិក |
| ៤ គ្រូជាស្ត្រីម្នាក់ | សមាជិក |

៥ នាយក ឬនាយករងសាលាបង្គោលម្នាក់ ទីប្រឹក្សា
៦ តំណាងក្រុមប្រឹក្សាឃុំ-សង្កាត់ម្នាក់ ទីប្រឹក្សា
៧ តំណាងជាប្រធានភូមិម្នាក់ ទីប្រឹក្សា

សមាជិកភាពនៃគណៈកម្មការគ្រប់គ្រងមូលដ្ឋាន គឺ ផ្តល់អទិភាពដល់ស្ត្រី គ្រប់កន្លែងដែលអាចធ្វើបាន សំរាប់ឋានៈខាងលើ ។

ជាពិសេស គណៈកម្មការគ្រប់គ្រងមូលដ្ឋាន នឹងអនុវត្តនូវកិច្ចការខាងក្រោមៈ

### ១ ការផ្សព្វផ្សាយការយល់ដឹង

ដើម្បីជ្រើសឱ្យបានសិស្សដែលនៅក្នុងគ្រួសារក្រីក្របំផុត មានសារៈសំខាន់នាស់ត្រូវផ្សព្វផ្សាយឱ្យមានការយល់ដឹងឱ្យបានច្រើនតាមដែលអាចធ្វើបានអំពីតំលៃនៃការអប់រំ ជាទូទៅ និងកម្មវិធីអាហារុពករណ៍ ជាពិសេស ។

សំរាប់ឆ្នាំសិក្សា ២០០៨-២០០៩ យុទ្ធសាស្ត្រចំនួនបីនឹងត្រូវអនុវត្តៈ

ផ្ទាំងរូបភាពងាហារូបករណ៍ រៀបរាប់ពីកម្មវិធី បង្ហាញពីកុមារីទៅសាលារៀន
ផ្ទាំងព័ត៌មានគន្លឹះៗ ពន្យល់លំអិតអំពីកម្មវិធីអាហារូបករណ៍ អាហារូបករណ៍សំរាប់អ្នកណា និងរបៀបដែលសិស្សដាក់ពាក្យសុំ
ការផ្សព្វផ្សាយតាមមាត់ គ្រូបង្រៀន មេភូមិ លោកសង្ឃ ផ្សព្វផ្សាយក្នុងអង្គប្រជុំ ឱ្យយល់ដឹងអំពីកម្មវិធីអាហារូបករណ៍ តើសំរាប់អ្នកណា និងរបៀបដែលសិស្សអាចដាក់ពាក្យសុំ ។

ការចូលរួមក្នុងកម្មវិធីអាហារូបករណ៍ជាការស្ម័គ្រចិត្ត ។ ពុំមានគ្រួសារ ឬ សិស្សណាម្នាក់តំរូវឱ្យចូលរួមឡើយ ។

### ២ ដំណើរការដាក់ពាក្យសុំអាហារូបករណ៍

សិស្សថ្នាក់ទីបីនឹងបំពេញពាក្យសុំអាហារូបករណ៍ ។ ហាក្យសុំនេះបានកែសំរួលពីពាក្យសុំដែលប្រើក្នុងកម្មវិធីអាហារូបករណ៍អនុវិទ្យាល័យ ។ ពុំមានសំនួរណាមួយដែលកំណត់ថាសិស្ស ត្រូវបាន ឬ មិនត្រូវបានអាហារូបករណ៍ឡើយ ។ តែ សំនួរនិមួយៗវាផ្តល់ទំងន់នៃភាពក្រីក្រខុស១គ្នា ហើយពិន្ទុសរុបនឹងកំណត់បាន

នូវសិស្សណាដែលនឹងត្រូវទទួលអាហារូបករណ៍។ ពាក្យសុំអាហារូបករណ៍នឹងត្រូវប្រមូលដោយនាយកសាលារៀនបឋមសិក្សា ដាក់ចូលក្នុងស្រោមសំបុត្រហើយបិទជិត ផ្ញើទៅការិយាល័យអាហារូបករណ៍ ក្រសួងអប់រំ តាមរយៈការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត ដើម្បីដាក់ពិន្ទុនៅថ្នាក់កណ្តាល។

សិស្សថ្នាក់ទីបីនឹងត្រូវធ្វើតេស្តថ្នាក់ទីបី លើមុខវិជ្ជា ភាសាខ្មែរ និងគណិតវិទ្យា។ ក្រដាសតេស្តនឹងត្រូវប្រមូលដោយនាយកសាលារៀនបឋមសិក្សា ដាក់ក្នុងស្រោមសំបុត្របិទជិតជូនដល់គណៈកម្មការគ្រប់គ្រងមូលដ្ឋាន ។ គណៈកម្មការគ្រប់គ្រងមូលដ្ឋាន នឹងផ្ញើស្រោមសំបុត្របិទជិតនេះទៅការិយាល័យអាហារូបករណ៍ ក្រសួងអប់រំ តាមរយៈការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត ដើម្បីដាក់ពិន្ទុនៅថ្នាក់កណ្តាល។

## ៣ ការជ្រើសរើសសិស្ស

អង្គភាពឯករាជ្យមួយនឹងដាក់ពិន្ទុលើពាក្យសុំអាហារូបករណ៍ ហើយតេស្តនឹងត្រូវកែដោយការិយាល័យប្រលង។ លទ្ធផលទទួលបាននឹងត្រូវតំរៀបគ្នាតាមលំដាប់ ដោយអង្គភាពឯករាជ្យខាងលើ ដើម្បីកំណត់រកសិស្សអាហារូបករណ៍ ដោយមានមូលដ្ឋានលើ កំរិតនៃភាពក្រីក្រ និង កំរិតនៃលទ្ធផលសិកសារបស់សិស្សម្នាក់ៗ។

## ៤ ការប្រកាសសិស្សអាហារូបករណ៍

នៅពេលនាដែលពាក្យសុំអាហារូបករណ៍ត្រូវបានដាក់ពិន្ទុ និងរៀបចំតាមលំដាប់ក្នុងបញ្ជី ការិយាល័យអាហារូបករណ៍ផ្ញើរបញ្ជី ឈ្មោះសិស្សដែលនឹងត្រូវទទួលអាហារូបករណ៍នេះ ជាសិស្សថ្នាក់ទី៤ ចំនួនពីរឆ្នាំបន្ទាប់ទៅ គណៈកម្មការគ្រប់គ្រងមូលដ្ឋាន តាមរយៈមន្ទីរអប់រំខេត្ត។ គណៈកម្មការគ្រប់គ្រងមូលដ្ឋាននឹងបិទបញ្ជីនេះចាប្រកាសពីសិស្សថ្នាក់ទីបួនដែលត្រូវ បានទទួលអាហារូបករណ៍លើ ក្តារខៀនផ្សព្វផ្សាយរបស់សាលារៀន ជាមួយនឹងប្រកាសកម្មវិធីអាហារូបករណ៍ដែលរៀបរាប់ច្បាស់លាស់ពីលក្ខណៈវិនិច្ឆ័យ និងបទបញ្ជារអាហារូបករណ៍។

## ៥ ការផ្តល់អាហារូបករណ៍

គណៈកម្មការគ្រប់គ្រងមូលដ្ឋានរៀនចំ ពិធីផ្តល់អាហារូបករណ៍ជាចំហ សំរាប់សិស្សថ្នាក់ទី ៤ ទី៥ និងទី៦ (បើដល់ឆ្នាំដែលមានសំរាប់ទី៥ និង៦) ដែលត្រូវទទួលអាហារូបករណ៍ ជាមួយនឹងឪពុកម្តាយឬអានាព្យាបាលរបស់គេ។ ចំនួនអាហារូបករណ៍សំរាប់សិស្សម្នាក់ និងគោលបំណងនៃអាហារូបលករណ៍នឹងត្រូវប្រកាសច្បាស់លាស់។

## ៦ យន្តការប្តឹងតវ៉ា

គណៈកម្មការគ្រប់គ្រងមូលដ្ឋាននឹងតាមអង្កេតរាល់បន្ទឹងតវ៉ា។ គណៈកម្មការគ្រប់គ្រងមូលដ្ឋាននឹងរៀបចំធ្វើការអង្កេតលើគ្រប់ពាក្យបណ្ដឹង ហើយបញ្ជូនការរកឃើយទៅការិយាល័យងាហារូបករណ៏។

ប្រសិនពេិបណ្ដឹងទាក់ទងនឹង ញ្ជីឈ្មោះសិស្សដែលបានជ្រើសរើសឱ្យទទួអាហារូបករណ៏ នោះបន្ដឹងនេះនឹងត្រូវទទួលបាននៅក្នុងរយៈមួយអាទិត្យ (៧ ថ្ងៃ) ពីថ្ងៃដែលបញ្ជីឈ្មោះនេះបានបិទផ្សាយ លើក្ដារខៀនសាលារៀន។

ពាក្យបណ្ដឹងពីបញ្ហាផ្សេងទៀតអាចទទួលយកនៅពេលណាក៏បានក្នុងឆ្នាំសិក្សា។

ផ្អែកលើការរកឃើញរបស់គណៈកម្មការគ្រប់គ្រងមូលដ្ឋាន ការិយាល័យអាហារូបករណ៏នឹងសំរេចលើការឆ្លើយតប ហើយទាក់ទងជាមួយនឹងអ្នកប្ដឹងចំពោះសកម្មភាពដែលនឹងត្រូវអនុវត្តដើម្បីឆ្លើយតប។